# បុគ្គលិកមូលដ្ឋានផ្នែកបុរសរួមភេទជាមួយបុរស
# បុគ្គលិកចល័ត (Outreach) / អ្នកអប់រំបង្គោល
# តេស្តកំណត់ចំណេះដឹងអំពី HIV/AIDS និង ភាមភាព

ឈ្មោះ : ______________________________ ថ្ងៃ ខែ ឆ្នាំ : ______________________________

អង្គការ : ______________________________ ប្រទេស : ______________________________

តើអ្នកមានតួនាទី ជាបុគ្គលិកមូលដ្ឋានផ្នែកបុរសរួមភេទជាមួយបុរស / បុគ្គលិកចល័ត /អ្នកអប់រំបង្គោល អស់រយៈពេលប៉ុន្មាន ?

ខែ / ឆ្នាំ នៃបទពិសោធន៍ការងារ : ______ ឆ្នាំ និង ______ ខែ

## A- **សំណួរស្តីពី** HIV **និង** AIDS

សូមគូសជាសញ្ញា បើអ្នកយល់ឃើញថា ប្រយោគខាងក្រោមនេះ " **ពិត** " " **មិនពិត** " ឬ " **មិនដឹង** " ។

( សូមគូសសញ្ញា " X " តាមជួរនិមួយៗ ) ។

| **សំណួរ** | **ពិត** | **មិនពិត** | **មិនដឹង/ មិនច្បាស** |
|---|---|---|---|
| ១- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមការរួមភេទមិនប្រើស្រោមអនាម័យ ជាមួយអ្នកដែលមិនដឹងពីស្ថានភាព HIV របស់ខ្លួន ឬ ដែល វិជ្ជមាន មេរោគ HIV | | | |
| ២- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមការគេងនៅក្នុងបន្ទប់ជាមួយអ្នកផ្ទុកមេរោគ | | | |
| ៣- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមការប្រើបន្ទប់ទឹកជាមួយអ្នកផ្ទុកមេរោគ | | | |
| ៤- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមការចាប់ដៃអ្នកផ្ទុកមេរោគ | | | |
| ៥- មនុស្សម្នាក់ដែលមើលទៅមានសុខភាពល្អ អាចជាអ្នកផ្ទុកមេរាគ HIV | | | |
| ៦- មនុស្សអាចការពារខ្លួនពីមេរោគ HIV បានដោយប្រើស្រោមអនាម័យយ៉ាងត្រឹមត្រូវរាល់ពេល រួមភេទ | | | |
| ៧- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមរយៈមូសខាំ | | | |
| ៨- មនុស្សម្នាក់អាចការពារខ្លួនពីមេរោគ HIV បានដោយមានដៃគូរួមភេទតែម្នាក់ ហើយដៃគូរនោះមិនមានផ្ទុកមេរោគ និង មិនមានដៃគូរណាផ្សេងទៀត | | | |
| ៩- មនុស្សម្នាក់អាចការពារខ្លួនពីមេរោគ HIV បានដោយមិនមានការរួមភេទជាមួយអ្នកណាសោះ | | | |
| ១០- មនុស្សម្នាក់អាចឆ្លងមេរោគ HIV តាមរយៈការប្រើម្ជុលដែលស្អាត និង ស្តេរិល (Sterile) | | | |

| | | | |
|---|---|---|---|
| ១១- មនុស្សម្នាក់អាចឆ្លងមេរោគ HIV បានតាមរយៈការប្រើម្ជុល រួមជាមួយអ្នកផ្ទុកមេរោគ | | | |
| ១២- មនុស្សម្នាក់អាចទប់ស្កាត់ការឆ្លងមេរោគ HIV បានដោយប្រើវិធីដកចេញនៅពេលរួមភេទ | | | |
| **សំណួរ** | **ពិត** | **មិនពិត** | **មិនដឹង** |
| ១៣- មេរោគ HIV អាចចម្លងបានតាមរយៈទឹកមាត់ និង ញើស | | | |
| ១៤- បើមនុស្សម្នាក់ផ្ទុកមេរោគ HIV នោះស្បែករបស់គាត់ជាទូទៅ គឺស្ងួត ហើយ ក្ដៅ | | | |
| ១៥- អ្នកផ្ទុកមេរោគ HIV ធម្មតា គឺស្គម ហើយស្លេក | | | |
| ១៦- មានឱសថដែលអាចព្យាបាលកំចាត់មេរោគ HIV និងជម្ងឺ AIDS បាន | | | |
| ១៧- មនុស្សម្នាក់អាចឆ្លងមេរោគ HIV បើគាត់ប្រើប្រាស់ដុះធ្មេញរួមជាមួយអ្នកផ្ទុកមេរោគ | | | |
| ១៨- មនុស្សម្នាក់អាចដឹងខ្លួនថា HIV វិជ្ជមាន ឬ អត់ តាមរយៈការធ្វើតេស្ត HIV នៅទីកន្លែងតេស្ត ដែលមានការទទួលស្គាល់ត្រឹមត្រូវតែប៉ុណ្ណោះ | | | |
| ១៩- ការសាក់លើខ្លួនអាចចម្លងមេរោគ HIV បើឧបករណ៏ដែលប្រើនោះមិនបានស្តេរីល (Sterile) | | | |
| ២០- ទោះជាអ្នកប្រើប្រាស់សារាងរួមគ្នាជាមួយនរណាម្នាក់ ក៏វាមានសុវត្ថិភាពដែរ ដរាបអ្នកប្រើម្ជុលថ្មី | | | |
| ២១- ការរួមភេទតាមផ្លូវមាត់ មានសុវត្ថិភាពជាងការរួមភេទតាមរន្ធគូថ | | | |
| ២២- ការរួមភេទតាមរន្ធគូថ ដោយមិនប្រើស្រោមអនាម័យនោះ វាមិនអីទេ បើដរាបណាអ្នកមិនបញ្ចេញទឹកកាមនៅក្នុងរន្ធគូថ | | | |
| ២៣- មនុស្សម្នាក់ដែលធាត់ មិនទំនងនឹងផ្ទុកមេរោគ HIV ដូចអ្នកដែលស្គមនោះទេ | | | |
| ២៤- អ្នកដែលមានលុយ មិនទំនងផ្ទុកមេរោគ HIVដូចអ្នកក្រទេ | | | |
| ២៥- ប្រើទឹកមាត់ជាប្រេងរំអិល វាមានសុវត្ថិភាពជាងមិនប្រើអ្វីទាំងអស់ | | | |
| ២៦- កាមរោគច្រើនតែឆ្លងតាមរយៈទឹកមាត់ និង លិង្គ មិនមែនតាមរយៈរន្ធគូថទេ | | | |
| ២៧- ការលេបទឹកកាមមានគ្រោះថ្នាក់តិចជាងការទទួលទឹកកាមចូលក្នុងរន្ធគូថរបស់អ្នក | | | |
| ២៨- បើអ្នកមានទំនាក់ទំនងស្នេហាជាមួយអ្នកណាម្នាក់លើសពី៦ខែនោះ អ្នកឈប់ប្រើស្រោមអនាម័យ ក៏បានដែរ | | | |
| ២៩- ទាល់តែមានសេចក្ដីក្លាហានខ្លាំងណាស់ ទើបយើងហ៊ានទៅទទួលការផ្ដល់យោបល់ និង ធ្វើតេស្ត HIV ប៉ុន្តែការប្រឹងប្រែងទាំងនោះ ទីបំផុតនឹងផ្ដល់ប្រយោជន៏ ដល់យើង | | | |
| ៣០- មានកាមរោគដែលមិនបានព្យាបាល នឹងធ្វើឱ្យឱកាសឆ្លងមេរោគ HIV កាន់តែកើនឡើង | | | |
| ៣១- អ្នកអាចមានជម្ងឺកាមរោគហើយមិនដឹងថាមាន | | | |
| ៣២- បើមនុស្សម្នាក់មើលទៅស្អាតបាត និង ក្មេងនោះ | | | |

| | | | |
|---|---|---|---|
| អ្នកមិនចាំបាច់ប្រើស្រោមអនាម័យជាមួយអ្នក នោះទេ | | | |
| ៣៣- ការរួមភេទតាមរន្ធគូថជាមួយដៃគូរ ១០នាក់ផ្សេងៗគ្នា ដោយប្រើស្រោមអនាម័យរាល់ពេល មានសុវត្ថិភាពជាងការរួមភេទតាមរន្ធគូថ ជាមួយដៃគូរតែម្នាក់តែមិនបានប្រើស្រោម | | | |
| **សំណួរ** | **ពិត** | **មិនពិត** | **មិនដឹង** |
| ៣៤- " ជ្រលក់ " (ឧទាហរណ៏: បញ្ចូលលិង្គទៅក្នុងរន្ធគូថមួយភ្លែត ដោយមិនបញ្ចេញទឹកកាម) មិន អាចចម្លងមេរោគ HIV បានទេ | | | |
| ៣៥- មនុស្សពីរនាក់ផ្ទុកមេរោគ HIV រួមភេទដោយមិនប្រើស្រោមអនាម័យ គឺធ្វើឱ្យគ្មានសុវត្ថិភាព សំរាប់ពួកគេ | | | |
| ៣៦- HIV ជាមេរោគមួយដែលប៉ះពាល់តែជនបរទេសប៉ុណ្ណោះ | | | |
| ៣៧- ស្រោមអនាម័យមានតែ ១ខ្នាតទេ | | | |
| ៣៨- យីហោ ឬ ឈ្មោះស្រោមអនាម័យទាំងអស់គុណភាពដូចៗគ្នា | | | |
| ៣៩- ការប្រើប្រេងរំអិលដែលមានជាតិខ្លាញ់ជាមួយស្រោមអនាម័យ គឺមានសុវត្ថិភាពធម្មតា | | | |
| ៤០- ប្រើប្រាស់ស្រោមអនាម័យ ដែលមានជាតិគីមីសម្លាប់ទឹកកាម (ស្ពែម) ការពារប្រឆាំងការឆ្លង មេរោគ HIV | | | |
| ៤១- ការកាត់ស្បែកអង្គជាតិរបស់បុរស ផ្តល់នូវការការពារប្រឆាំងមេរោគ HIV | | | |
| ៤២- វាមិនថ្វីទេបើយើងមិនប្រើស្រោមអនាម័យជាមួយបុរស ដែលស្បែកអង្គជាតិត្រូវបានកាត់ចោល | | | |
| ៤៣- ឱកាសឆ្លងមេរោគ HIV ពីការប្រើមាត់ ឬ អណ្តាតទៅលើរន្ធគូថ គឺតិចតួចណាស់។ ប៉ុន្តែអ្នក អាចឆ្លងជម្ងឺថ្លើម Hepatitis ឬ កាមរោគដទៃយ៉ាងងាយ | | | |

## B- សំណួរស្តីពីភាពរួមភេទជាមួយភេទដូចគ្នា ( ភាពខ្ទើយ)

| **សំណួរ** | **យល់ស្រប** | **មិនយល់ស្រប** | **មិនដឹង/ មិនច្បាស់** |
|---|---|---|---|
| ៤៤- ភាពរួមភេទជាមួយភេទដូចគ្នា (ភាពខ្ទើយ) កើតឡើងដោយសារក្មេងប្រុសៗ កាលនៅតូច នៅក្បែរក្មេងស្រីៗច្រើនពេក | | | |
| ៤៥- ភាពរួមភេទជាមួយភេទដូចគ្នា កើតឡើងដោយសារបុរស ខ្វះជាតិអ័រម៉ូនមនុស្សប្រុស (Testosterone) | | | |
| ៤៦- ភាពរួមភេទជាមួយភេទដូចគ្នា មួយចំណែកគឺជារចនាបថ (ស្ទីលដែលទាន់សម័យ) | | | |

| | | | |
|---|---|---|---|
| ៤៧- ភាពរួមភេទជាមួយភេទដូចគ្នា កើតឡើងនៅក្នុងវប្បធម៌ និង ប្រទេសទាំងអស់នៅក្នុងពិភពលោក | | | |
| ៤៨- អ្នករួមភេទជាមួយភេទដូចគ្នាមានឱកាសឆ្លងមេរោគ HIV ច្រើនជាងអ្នករួមភេទជាមួយភេទខុសគ្នា បើពួកគេមិនប្រើស្រោមអនាម័យ | | | |
| **សំណួរ** | **យល់ស្រប** | **មិនយល់ស្រប** | **មិនដឹង/មិនច្បាស់** |
| ៤៩- កម្មវិធី កម្មសិក្សា និង សមាធិ សំរាប់បញ្ឈប់អារម្មណ៍រួមភេទជាមួយភេទដូចគ្នាមានប្រសិទ្ធិភាពណាស់ | | | |
| ៥០- ភាពរួមភេទជាមួយភេទដូចគ្នា គឺជាធម្មជាតិ | | | |
| ៥១- ឥរិយាបថរួមភេទជាមួយភេទដូចគ្នា គឺមានបាបកម្ម | | | |
| ៥២- " បុរសពិត " អាចក្លាយជាខ្ទើយ បើពួកគេមានទំនាក់ទំនងជាមួយអ្នករួមភេទ ជាមួយភេទដូចគ្នា (ខ្ទើយ) ច្រើនពេក | | | |
| ៥៣- ការប្រព្រឹត្តការរួមភេទតាមរយៈរន្ធគូថជាមួយស្ត្រី អាចធ្វើឱ្យអ្នកខ្ទើយ | | | |
| ៥៤- ភាពខ្ទើយកើតឡើងចំពោះអ្នកមានជីវភាព ឋានៈគួរសម ច្រើនជាងចំពោះអ្នកមានជីវភាពឋានៈក្រីក្រ | | | |
| ៥៥- ការរួមភេទតាមរន្ធគូថដោយបញ្ចូល គឺមិនសូវអាចចម្លងមេរោគ HIV ដូចការរួមភេទតាមរន្ធគូថដោយទទួល | | | |
| ៥៦- បុរសរួមភេទជាមួយបុរស (MSM) អាចប្រើស្រោមអនាម័យស្ត្រីបាន នៅពេលរួមភេទតាមរន្ធគូថ | | | |
| ៥៧- ពួកខ្ទើយ (អ្នករួមភេទជាមួយភេទដូចគ្នា) ជាមូលហេតុនៃរោគរាតត្បាត HIV នេះ | | | |
| ៥៨- ភាពខ្ទើយកើតឡើងតែនៅទីក្រុង មិនមាននៅជនបទទេ | | | |

## C- សំណួរស្តីពីអ្នកដែលរស់នៅផ្ទុក HIV និង AIDs

| **សំណួរ** | **យល់ស្រប** | **មិនយល់ស្រប** | **មិនដឹង/មិនច្បាស់** |
|---|---|---|---|
| ៥៩- វាជាការប្រសើរបំផុត ដែលត្រូវផ្តល់យោបល់ទៅអ្នកផ្ទុក HIV កុំឱ្យរួមភេទ | | | |
| ៦០- អ្នកដែលមាន HIV ឬ AIDs ត្រូវតែប្រើស្រោមអនាម័យ២ មិនមែនតែមួយទេ ដើម្បីឱ្យប្រាកដ | | | |
| ៦១- ប្រសិនបើអ្នករស់នៅផ្ទុកមេរោគ HIV ប្រើថ្នាំ Antiretroviral ឱ្យបានត្រឹមត្រូវពួកគេ | | | |

| | | | |
|---|---|---|---|
| អាចរស់នៅអាយុវែង និង សុខភាពល្អ | | | |
| ៦២- មនុស្សខ្លះអាចរស់នៅជាមួយមេរោគ HIV បានលើសពី ២០ឆ្នាំ | | | |
| ៦៣- វាជាការប្រសើរបំផុតដែលយើងសន្មត់ថា មនុស្សគ្រប់គ្នាផ្ទុកមេរោគ HIV នៅពេលដែលយើងស្វែងរកការរួមភេទដើម្បីសប្បាយលេង | | | |
| ៦៤- មនុស្សមានមេរោគ HIV គឺដោយសារកំហុសរបស់ខ្លួនផ្ទាល់ | | | |
| ៦៥- ជាធម្មតាអ្នកផ្ទុកមេរោគ HIV ធ្លាប់មានការរួមភេទ ឬ ប្រើគ្រឿងញៀនច្រើនជាងអ្នកដែលមិនផ្ទុកមេរោគ HIV | | | |
| ៦៦- នៅទីក្រុងខ្លះដូចជាបាងកក លើសពី ២៥% នៃបុរសរួមភេទជាមួយបុរស ដែលទៅកន្លែងកំសាន្តសប្បាយ មានមេរោគ HIV ឬជម្ងឺ AIDS | | | |
| ៦៧- អ្នកដែលមានមេរោគ HIV ឬជម្ងឺ AIDS គួរតែពិនិត្យចំនួន CD-4 របស់ពួកគេជាប្រចាំ | | | |
| ៦៨- ការស្ងប់ផ្លូវចិត្ត ការហាត់កីឡាជាប្រចាំ និង របបអាហារដ៏ល្អ នឹងជួយឱ្យអ្នកមានមេរោគ HIV និងជម្ងឺ AIDs ឱ្យរស់នៅមានសុខភាពល្អបានយូរ | | | |
| ៦៩- អ្នកដែលទើបនឹងឆ្លងមេរោគ HIV ភ្លាមៗងាយអាចចម្លងទៅមនុស្សម្នាក់ទៀតតាមរយៈការរួម ភេទដែលគ្មានសុវត្ថិភាព ច្រើនជាងអ្នកដែលផ្ទុកមេរោគរាប់ឆ្នាំហើយ | | | |
| ៧០- អ្នកប្រើថ្នាំ ARV ដែលមិនដឹងថាចំនួនមេរោគ HIV ក្នុងខ្លួនមានដល់ណា អាចចម្លង HIV ទៅដៃគូរនៅពេលរួមភេទតាមរន្ធគូថដោយគ្មានសុវត្ថិភាព ស្មើនឹងអ្នកដែលផ្ទុកមេរោគ HIV តែមិនប្រើថ្នាំ ARV | | | |

## D- សំណួរចំហរ ( គ្មានចម្លើយ "ពិត" ឬ "មិនពិត" សំរាប់ផ្នែកនេះទេ)

ឧបមាថា អ្នកជួបបុរសវ័យកណ្តាលម្នាក់ ហើយគាត់ប្រាប់ថា គាត់មិនចង់ប្រើស្រោមអនាម័យទេ ពីព្រោះវាកាត់បន្ថយការសប្បាយគាត់។ គាត់និយាយផងថា គាត់គ្រាន់តែជាអ្នកបញ្ចូលនូវពេលរួមភេទតាមគូថ ហើយគាត់ថាវាមិនមែនជាការប្រថុយឆ្លងមេរោគហ៊ីវទេ។ តើអ្នកនឹងនិយាយទៅកាន់គាត់យ៉ាងដូចម្តេចខ្លះ?

| |
|---|
| |

ឧបមថា អ្នកជួបបុរសពីរនាក់ដែលជាសង្សារនឹងគ្នា អស់រយៈពេល៦ខែហើយ ពួកគេនិយាយថា ពួកគេជាគូរស្នេហ៍ស្មោះមួយនឹងមួយ ។ គេសួរអ្នកថា តើគេអាចឈប់ប្រើស្រោមអនាម័យបានទេ ។ តើអ្នកនឹងផ្តល់យោបល់យ៉ាងណាចំពោះពួកគេ?

ឧបមាថា អ្នកស្គាល់បុរសក្មេងម្នាក់នៅកន្លែងធ្វើការ ហើយបុរសរូបនោះរួមភេទជាមួយបុរសដទៃអស់រយៈពេលជាយូរ ។ ឥឡូវឪពុកម្តាយគាត់ រៀបចំឱ្យគាត់រៀបការជាមួយនារីម្នាក់ ។ បុរសនោះមិនច្បាស់ថា គាត់ត្រូវធ្វើយ៉ាងណាទេ ។ តើអ្នកនឹងផ្តល់យោបល់គាត់យ៉ាងណាខ្លះ?

ពិពណ៌នាអំពីករណីដែលលំបាកបំផុត ដែលអ្នកធ្លាប់បានជួបប្រទះក្នុងការងារនេះ។ អ្វីទៅដែលបានធ្វើឱ្យវាពិបាក? តើអ្នកដោះស្រាយ វាតាមវិធីណា ?

តើអ្នកចង់បានការជំនួយ ឬ គាំទ្រអ្វីដែលអាចធ្វើឱ្យការងារអ្នកងាយស្រួលជាមុន?